អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីប្រកាសព័ត៌មាន

អង្គភាពជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានទទួលជំនួយថវិកាពីសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់។ ក្នុងរយៈពេលពីរឆ្នាំ អង្គការ GTZ ដែលគ្រប់គ្រងការងារដោយការិយាល័យការបរទេសអាល្លឺម៉ង់ នឹងផ្តល់ថវិកាចំនួន **១.៥** លានយូរ៉ូដើម្បីជួយឧបត្ថម្ភគាំទ្រដល់ការងារអង្គភាពជនរងគ្រោះ។

ពិធីចុះហត្ថលេខាជាផ្លូវការត្រូវបានប្រព្រឹត្តធ្វើឡើងនៅឯមជ្ឈមណ្ឌលព័ត៌មានរបស់អ.វ.ត.កក្នុងក្រុងភ្នំពេញដោយមានការចូលរួមពីសំណាក់ឯកឧត្តម ស៊ាន វិសុទ្ធ ប្រធានការិយាល័យរដ្ឋបាល និងលោកជួរហ្គិន ស្ស៊ីលលីង Juergen Schilling នាយកអង្គការ GTZ ប្រចាំប្រទេសកម្ពុជា។ កិច្ចព្រមព្រៀងចំនួន៣៖ កិច្ចព្រមព្រៀងលើការអនុវត្តន៍គំរោង កិច្ចព្រមព្រៀងផ្នែកហិរញ្ញវត្ថុ និងកិច្ចព្រមព្រៀងពិសេសទាក់ទងនឹងគំរោងគាំទ្រដល់ការងាររបស់អង្គភាពជនរងគ្រោះ ត្រូវបានចុះហត្ថលេខានៅក្នុងពិធីនេះ។

ថវិកាជំនួយដែលសាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ផ្តល់ដល់អ.វ.ត.កសំរាប់ប្រតិបត្តិការការងាររបស់ខ្លួន គិតមកដល់ពេលនេះ មានចំនួនសរុបជិត១០ លានដុល្លាអាមេរិក។

អង្គភាពជនរងគ្រោះរបស់អ.វ.ត.ក គឺជាមជ្ឈមណ្ឌលទំនាក់ទំនងកណ្តាលមួយសំរាប់ជនរងគ្រោះនិងតំណាងរបស់ខ្លួនក្នុងការដាក់ពាក្យចូលរួមក្នុងដំណើរការរបស់តុលាការ។

រហូតមកដល់ពេលនេះអង្គភាពជនរងគ្រោះបាទទួលពាក្យបណ្តឹងនិងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៥០០ ពីសំណាក់ជនរងគ្រោះក្នុងរបបខ្មែរក្រហម។ អង្គភាពជនរងគ្រោះត្រូវបានបង្កើតឡើងដើម្បីជួយសម្របសម្រួលដល់ការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការនីតិវិធីតុលាការ។ តួនាទីចំបងរបស់អង្គភាពជនរងគ្រោះគឺ ថែរក្សាបញ្ជីឈ្មោះមេធាវីដែលមានបំណងធ្វើជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការនីតិវិធីតុលាការ និងធានាដល់ជនរងគ្រោះឲ្យមានតំណាងផ្លូវច្បាប់ប្រកបដោយគុណភាពល្អ។

ឯកឧត្តម ស៊ាន វិសុទ្ធ បានមានប្រសាសន៍ថាចាប់តាំងពីអ.វ.ត.កបានដំណើរការមក មានការវិវត្តន៍រីកចម្រើនគួរឲ្យកត់សំគាល់ជាមួយនឹងការចោទប្រកាន់និងឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទចំនួន៥ រូបរង់ចាំការជំនុំជម្រះក្តី។ ឯកឧត្តមបានបន្ថែមទៀតថាអ.វ.ត.ក ផ្តល់ឱកាសជាប្រវត្តិសាស្ត្រដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហមដ៏ឃោរឃៅក្នុងការទទួលបានយុត្តិធម៌ហើយអ.វ.ត.ក គឺជាតុលាការអន្តរជាតិឬតុលាការកូនកាត់លើកទីមួយដែលមានការចូលរួមយ៉ាងពេញលេញពីសំណាក់ជនរងគ្រោះដែលជាចំណែកមួយក្នុងការចូលរួមដល់ការអភិវឌ្ឍច្បាប់អន្តរជាតិ។

**ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៨**

ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh